# ការជ្រើសរើសបេក្ខជនសម្រាប់រដ្ឋសភាយុវជនត្រាប់

## ១.សាវតារ និងគោលបំណង

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) ជាសម្ព័ន្ធនៃអង្គការ សមាគមជាតិ និងអន្តរជាតិជាង២០ ដែលបានធ្វើការរួមដើម្បីការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា។ នាពេលថ្មីៗនេះ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោតបានរៀបចំសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីផ្តល់ជូនទៅគណៈកម្មការចម្រុះនៃគណបក្សទាំងពីរដើម្បីឱ្យពិចារណាទទួលយកសេចក្តីស្នើច្បាប់នេះ។

ជាផ្នែកមួយនៃការពិភាក្សា និងពិគ្រោះយោបល់ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត រួមទាំងអង្គការសមាគមក្រៅរដ្ឋាភិបាលមួយចំនួនទៀត បានសហការរៀបចំកម្មវិធីរដ្ឋសភាយុវជនត្រាប់មួយ ក្នុងបំណង៖

- បង្កើតឱ្យមានការពិភាក្សាទៅលើសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ជ.ប (រៀបចំដោយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត) ដោយតំណាងរដ្ឋសភាយុវជន ខណៈដែលពួកគេអាចអនុម័ត ឬ/ និងកែលម្អសេចក្តីស្នើច្បាប់នេះ។
- បង្កើនការយល់ដឹងអំពីសេចក្តីស្នើច្បាប់នេះនៅក្នុងចំណោមតំណាងយុវជនចំនួន ១២៣រូប ដើម្បីជាចំណេះ ដឹងសម្រាប់ចូលរួមក្នុងសកម្មភាពបោះឆ្នោតនាពេលអនាគត។
- សិក្សាអំពីដំណើរការពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា និងដើរតួជាអ្នកតំណាងរាស្ត្រ និងដើម្បីចូលរួមក្នុងរដ្ឋសភា។

អាស្រ័យដូចនេះ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត ត្រូវការជ្រើសរើសយុវនចំនួន ១៤៣រូប ដើម្បីចូលរួមធ្វើការពិភាក្សា និងអនុម័ត ទៅលើសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ជ.ប ព្រមទាំងចូលរួមសង្កេតការក្នុងដំណើរការពិភាក្សានេះ។

## ២. លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើស

- ជានិស្សិត
- អាយុពី ១៧ ដល់ ៣០ឆ្នាំ
- មានការតាំងចិត្តខ្ពស់ក្នុងការចូលរួម (ពេលវេលា)

## ៣. ពេលវេលា

- ការបណ្តុះបណ្តាល៖ ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (រយៈមួយព្រឹក)
- ការពិភាក្សា និងអនុម័ត៖ ថ្ងៃទី ១៤ ១៥ ១៦ និង ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ៤. តួនាទី និងការទទួលខុសត្រូវរបស់យុវជន

- ចូលរួមក្នុងវគ្គណែនាំអំពីនីតិវិធីប្រជុំរបស់រដ្ឋសភា និងការសង្កេតការ
- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងអនុម័ត

**៥. អត្ថប្រយោជន៍ទទួលបាន**

- ចំណេះដឹងពីសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប របស់ ERA
- ចំណេះដឹងពីការពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា និងការសង្កេតការ
- លិខិតបញ្ជាក់ការចូលរួម

**៦. ការដាក់ពាក្យ**

ចំពោះបេក្ខជនដែលចាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និងលិខិតបង្ហាញពីចំណាប់អារម្មណ៍ទៅកាន់អ៊ីម៉ែល៖ **yuthyia@comfrel.org** ឱ្យបានមុនថ្ងៃទី**២៤ ខែតុលា ឆ្នាំ២០១៤** ដោយបញ្ជាក់ថា អ្នកចង់ធ្វើជាតំណាងរាស្ត្រ ឬអ្នកសង្កេតការ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមទូរស័ព្ទលេខ៖ **088 81 42 783**